SPRING PARKS PRIMARY SCHOOL
*Learning and Growing-Safely-Together*

*សារសំរាប់សហគមន៏សាលា,*

*ជំរាបលោកអ្នកជាមាតាបិតា,អាណាព្យាបាល,សិស្សានុសិស្សនិងបុគ្គិកសាលា,*

*យោងទៅតាមការណែនាំពីប្រធានផ្នែកសុខាភិបាល,ក្នុងថ្ងៃនេះ,រដ្ឋាភិបាលនៃរដ្ឋវិចតូរីយ៉ាបានប្រកាសថា,តំបន់និងជនបទទាំងឡាយត្រូវឈានទៅការដាក់ក៏រឹតដំណាក់ការទី៣,ហើយតំបន់នានានៃក្រុងម៉ែលប៊ុននឹងឈានដល់ការដាក់ក៏រឹតដំណាក់ការទី៤ដើម្បីបន្ថយការឆ្លងរីកដាលនៃមេរោគកូវិដ-១៩។*
*តម្រូវការនេះនឹងអនុវត្តដល់សាលារដ្ឋ,សាលាកាតូលិក,សាលាឈ្នួលនៅក្នុងតំបន់ជនបទទូរទាំងក្រុងម៉ែលប៊ុននៃរដ្ឋវិចតូរីយ៉ា។*

*ការផ្លាស់ប្តូររបៀបរៀនសូត្រនឹងចាប់ផ្តើមអនុវត្តចាប់ពី ថ្ងៃពុធទី៥ខែសីហា,ក្រោយពីថ្ងៃអង្គារទី៤ខែសីហាដែលជាថ្ងៃដែលសិស្សបានឈប់សំរាក១ថ្ងៃ,ហើយការផ្លាស់ប្តូរនេះអាចអនុវត្តបន្តរហូតដល់ចុងត្រីមាសទី៣។*

*ដូចបានណែនាំពីប្រធានផ្នែកសុខាភិបាលនៅថ្ងៃសុក្រថា,សាលានៅតែជាទីកន្លែងសុខបំផុតសំរាប់បុគ្គលិកនិងសិស្សសាលា-ក៏ប៉ុន្តែវិធានការណ៏នេះបានចាត់ចែងឡើងគឺដើម្បីបន្ថយចំនួនសិស្សនិងគ្រួសារធ្វើដំណើរទៅមកក្នុងរដ្ឋ។*

*មានការបះពាល់ខ្លះចំពោះសាលាយើងហើយនឹងគ្រួសារក្នុងសហគមន៏សាលា ។*
*ខាងក្រោមនេះជាសេចក្តីសង្ខេបថាតើការផ្លាស់ប្តូរនេះមានន័យយ៉ាងដូចម្តេចៈ*

## ***តំបន់នានានៃក្រុងម៉ែលប៊ុន***

*ថ្នាក់មូលដ្ឋានដល់ថ្នាក់ទី១០:*

- *ថ្នាក់មូលដ្ឋានដល់ទី១០បន្តការរៀននៅផ្ទះដូចធម្មតា*
- *លក្ខណ្ឌសំរាប់សិស្សដែលអាចមកសាលារៀនក្នុងពេលសិស្សដទៃត្រូវរៀននៅផ្ទះមានការផ្លាស់ប្តូរដូចតទៅៈ*
  *-កុមារដែលមានឪពុកម្តាយទៅធ្វើការឬប្រកបមុខរបរក្នុងវិស័យណាដែលរដ្ឋអនុញ្ញាតិឲ្យធ្វើ។រដ្ឋនឹងជូនពត៍មានក្បោះក្បាយអំលក្ខណ្ឌនេះ*
  *-កុមារងាយរងគ្រោះដែលមិននៅផ្ទះជាមួយឪពុកម្តាយ(ដូចជាត្រូវទៅនៅជាមួយជីដូនជីតា,មាមីងជាដើម),កុមារដែលមានការទទួលស្គាល់ពីអង្គការការពារកុមារនិងអង្គការដទៃថាងាយរងគ្រោះហើយនឹងកុមារដែលសាលាទទួលស្គាល់ថាងាយរងគ្រោះ*
  *-កុមារមានពិការភាពហើយស្របនឹងលក្ខ័ណ្ឌ១នៃលក្ខ័ណ្ឌទាំងពីរនៅខាងលើ*

***ពេលវេលា:***

- *ថ្ងៃច័ន្ទទី៣ ខែ សីហា ជាថ្ងៃរៀន្ន"ធម្មតា"ចំពោះសាលាលស្ថិតក្នុងការចាត់ចែងដូចបច្ចុប្បន,។ចំពោះសិស្សដែលមករៀននៅសាលាក្នុងថ្ងៃនេះ,ត្រូវយកសម្ភារៈសិក្សាចាំបាច់ទៅរៀននៅផ្ទះ*
- *ថ្ងៃអង្គារទី៤ ខែ សីហា, ជាថ្ងៃដែលសិស្សទាំងឡាយបានឈប់សំរាកដើម្បីឲ្យគ្រូមានពេលរៀបចំការរៀនពីចម្ងាយ*
- *ថ្ងៃពុធទី៥ ខែ សីហា ជាថ្ងៃទីមួយនៃការរៀនពីចម្ងាយសំរាប់សាលាទាំងឡាយក្នុងរដ្ឋវិចតូរីយ៉ា*

*ការរៀបចំចាត់ចែងបុគ្គលិកត្រៀមធ្វើការក្នុងសាលា*

- *សាលានឹងធនាថាមានគ្រប់ចំនួនបុគ្គលិកដើម្បីជួយត្រួតពិនិត្យសិស្សដែលមានគ្រប់លក្ខ័ណ្ឌមករៀននៅសាលាក្នុងពេលសិស្ស ដទៃត្រូវរៀននៅផ្ទះ*
- *ចំពោះបុគ្គលិកណាដែលមិនត្រូវមកសាលាជួយត្រួតពិនិត្យនោះទេ,នឹងចាត់ចែងឲ្យធ្វើការនៅផ្ទះ*

*ខ្ញុំននឹងបន្តជូនដំណឹងថ្មីៗចំពោះការចាត់ចែងទាក់ទងទៅនឹងការរៀនពីចម្ងាយសំរាប់សាលាយើង។*
*សូមអរគុណ*

Julie Fisher
*នាយកសាលា*